ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមិថុនា ឆ្នាំ២០១៥

*នៅក្នុងខែមិថុនា ឆ្នាំ២០១៥នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:*

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ពេលបំពេញមុខតំណែងជាអនុប្រធានទី១ ព្រឹទ្ធសភា និងបន្ទាប់មកជាប្រធានព្រឹទ្ធសភា បាន៖**

*-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា*

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងសម័យប្រជុំវិសាមញ្ញចំនួន០១លើក និងពេញអង្គចំនួន០១លើក*

*-ត្រូវបានជ្រើសតាំងជាប្រធានព្រឹទ្ធសភាតាមរយៈការបោះឆ្នោតជ្រើសតាំង នាសម័យប្រជុំវិសាមញ្ញថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥*

*-ទទួលគោរមងារជា**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ពី **ព្រះករុណា ព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា*

*-ទទួលភារកិច្ចជាអនុប្រធានគណៈកម្មការរៀបចំពិធីបុណ្យសព **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម***

*-អញ្ជើញចូលរួមព្រះរាជពិធីថ្វាយព្រះបរមងារកិត្តិយសថ្នាក់ខ្ពស់បំផុតខាងព្រះពុទ្ធសាសនា " **ព្រះស្រីលោកធម្មិករាជ** " ថ្វាយព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង*

*-ទទួលឯកឧត្តម **ឡេ ថាញ់ហាយ** សមាជិកការិយាល័យនយោបាយមជ្ឈឹមបក្សកុម្មុយនីស្តវៀតណាម និងជាលេខាគណៈកម្មាធិការបក្សទីក្រុងហូជីមិញ ចូលជួបសវនាការ និងសម្តែងការគួរសម*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-ទទួលឯកឧត្តម Ryu SHIONOYA សមាជិករដ្ឋសភាជប៉ុននិងជាបេសកជនពិសេសរបស់នាយករដ្ឋមន្ត្រីជប៉ុន ចូលជួបសវនាការ និងសម្តែងការគួរសម

-ទទួលឯកឧត្តម Sakthip Krairiksh ប្រធានក្រុមមិត្តភាពសភាថៃ-កម្ពុជា និងជាសមាជិកសភានីតិប្បញ្ញត្តិ ព្រមទាំងគណៈប្រតិភូ ចូលជួបសវនាការ និងសម្តែងការគួរសម

-អញ្ជើញជួបសំណេះសំណាលជាមួយគណៈគ្រប់គ្រង និងបុគ្គលិកសិក្សា នៅវិទ្យាល័យច្បារអំពៅ ព្រមទាំងប្រគល់ទីលានបាល់ទាត់ថ្មីមួយ(ជាអំណោយផ្ទាល់របស់សម្តេច និងសប្បុរសជននានា)ដាក់ឲ្យប្រើប្រាស់ជាផ្លូវការ

-អញ្ជើញប្រារព្ធពីធីបង្សុកូល និងគោរពវិញ្ញាណក្ខន្ធសពព្រះព្រហ្មធម្ម **ស៊ីវ គឹមសន** រាជាគណៈថ្នាក់កិត្តិយស និងជាព្រះមុនីសត្ថាចារ្យកោសល ព្រះមេគណខេត្តកំពង់ស្ពឺ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៨២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥០ច្បាប់ ។

**១.២.ឯកឧត្តម ងៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា ប្បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងសម័យប្រជុំវិសាមញ្ញចំនួន០១លើក និងពេញអង្គចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបូជាសព**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា

-អញ្ជើញទទួលដំណើរគណៈប្រតិភូនៃសាធារណរដ្ឋប្រជាមានិតឡាវ អញ្ជើញមកចូលរួមគោរពវិញ្ញាណក្ខន្ធសព**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាប្បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងសម័យប្រជុំវិសាមញ្ញចំនួន០១លើក និងពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យសព**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងជំនួបសវនាការរវាងសម្តេចអគ្គមហាពញាចក្រី

*ហេង សំរិន* ប្រធានរដ្ឋសភា ជាមួយឯកឧត្តម Nguyen Sinh Hung ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញជាអធិបតីថ្លៃងសុន្ទរកថាបិទសិក្ខាសាលាស្តីពី " ការឈ្វេងយល់ពីច្បាប់ និងការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ"

-អញ្ជើញជាអធិបតីថ្លៃងសុន្ទរកថាបើកវេទិកាភូមិភាគ៤ ស្តីពី " ការលើកកម្ពស់សមត្ថភាព និងពង្រឹងអភិបាលកិច្ចក្នុងការអភិវឌ្ឍមូលដ្ឋាន" នៅខេត្តសៀមរាប

-អញ្ជើញជាអធិបតីថ្លៃងសុន្ទរកថាបើកវេទិកាភូមិភាគ៧ស្តីពី " គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការលើកកម្ពស់សេវាសាធារណៈ " នៅខេត្តពោធិ៍សាត់

-អញ្ជើញទទួលគណៈប្រតិភូដឹកនាំដោយឯកឧត្តម Nguyen Sinh Hung ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងជូនឯកឧត្តមអនុរដ្ឋមន្ត្រីនៃគណៈទាក់ទងបរទេស នៃសាធារណរដ្ឋប្រជាមានិតចិន

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៤២ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើកដើម្បី ៖**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០១ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំពេញអង្គ និងប្រជុំវិសាមញ្ញព្រឹទ្ធសភា៖

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ២៩/១៥លគ.គក ចុះថ្ងៃទី០៨ ខែមិថុនាឆ្នាំ២០១៥ ។

២.ពិនិត្យ និងសម្រេចលើសំណើរបស់សមាជិកព្រឹទ្ធសភា ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០១៥ ស្នើសុំកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ។

៣.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។

៤.ពិនិត្យ និងសម្រេចលើសេចក្តីព្រាងរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ នីតិកាលទី៣ ។

៥.កំណត់របៀបវារៈ កាលបរិច្ឆេទ និងសមាសភាពលេខាធិការសម័យប្រជុំ លើកទី ៧ ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.សម័យប្រជុំវិសាមញ្ញចំនួន០១លើក និងពេញអង្គចំនួន០១ដើម្បី៖**

១.បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៣

២.ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី

៣.ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ ព្រឹទ្ធសភា នីតិកាលទី៣

៤.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

**៤. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមិថុនានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន០១ ។

-ប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីព្រាងសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា និងឯកសារពាក់ព័ន្ធ ។

-ប្រជុំរួមយោបល់លើសេចក្តីព្រាងនៃការសិក្សាបឋមអំពីការងារនីតិកម្ម ការធ្វើវិសោធនកម្ម គម្រោងធ្វើវិសោធនកម្មច្បាប់ជាធរមាន និងគម្រោងតាក់តែងច្បាប់ថ្មី

**៤.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងបានចំនួន១៤ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីក្រសួងយុត្តិធម៌ចំនួន០១ករណី ទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន០៣ករណី ។

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ៨ ស្តីពីសកម្មភាពការងាររបស់ក្រុម នៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ និងពិនិត្យពិភាក្សាលើគម្រោងរៀបចំវេទិកានៅខេត្តមណ្ឌលគិរី និងខេត្តព្រៃវែង ។

-ប្រជុំពិភាក្សាអំពីការបង្កើតក្រុមកិច្ចសហប្រតិបត្តិការព្រឹទ្ធសភា ជាមួយសភា

បណ្តាប្រទេស និងក្រុមការងារផ្សេងៗ

-ប្រជុំពិភាក្សាអំពីការងារទំនាក់ទំនង និងការងារដំណើរការសកម្មភាព នៃក្រុមមិត្តភាពកម្ពុជា-ជប៉ុន

-ប្រជុំពិភាក្សាការងារជាមួយលោក Hakan ATASEVER ប្រធានវិទ្យាស្ថានសន្ទនាមេគង្គ

-ប្រជុំត្រៀមលក្ខណៈមុនចេញដំណើរទៅទស្សនកិច្ចសិក្សាស្វែងយល់ស្តីពីតួនាទីរបស់គណបក្សនយោបាយនៅក្នុងសភា នៅសាធារណរដ្ឋបារាំង

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការបង្កើតច្បាប់ និងការពិនិត្យច្បាប់ដោយរដ្ឋសភា "

-បទបង្ហាញអំពីលទ្ធផលនៃទស្សនកិច្ចសិក្សាអំពី " គំរូ និងបែបបទនៃដំណើរការរបស់ការិយាល័យថវិកាសភា (PBO) "

-កិច្ចពិគ្រោះយោបល់ស្តីពី " ការអនុវត្តអនុសញ្ញា នៃការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ" CEDAN " និង " ការតាក់តែងច្បាប់ និងការត្រួតពិនិត្យច្បាប់ដោយសភាកម្ពុជា "

-រៀបចំសិក្ខាសាលាស្តីពីការស្វែងយល់ពីច្បាប់ និងការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ចម្រុះគណបក្សស្តីពីស្ថានភាព នៃការតាក់តែងច្បាប់ ការអនុវត្តក្នុងការត្រួតពិនិត្យច្បាប់របស់រដ្ឋសភាកម្ពុជា

-ទទួលជួបឯកឧត្តមឯក**អគ្គរដ្ឋទូតចិន ឯកអគ្គរដ្ឋទូតឡាវ** ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **សូមផាន ផែនខាំមី** អនុប្រធានទី២ និងជាប្រធានក្រុមមិត្តភាពឡាវ-កម្ពុជា នៃសភាជាតិឡាវ ចូលជួបសម្តែងការគួរសម និងពិភាក្សារការងារ

-អនុញ្ញាតឲ្យលោក **ដារ៉ារិទ្ធ គឹមយាត** នាយកវិទ្យាស្ថានសភាកម្ពុជា និងក្រុមការងារជួបពិភាក្សាការងារ

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១២៤លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខគ្រួសារជនរងគ្រោះ និងចូលរួមរំលែកទុក្ខគ្រួសារសពដែលជួបគ្រោះថ្នាក់ចរាចរណ៍ សមាជិក

ក្រុមប្រឹក្សាឃុំ-សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១១០លើក។

**៤.៣. មុខងារត្រួតពិនិត្យ**

-ជួបសវនាការជាមួយថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ដើម្បីស្តាប់របាយការណ៍និងឈ្វេងយល់អំពីការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ នៅទីស្តីការក្រសួងពាណិជ្ជកម្ម។

**៤.៤. មុខងារព័ត៌មាន**

-អញ្ជើញចុះបេសកកម្ម សិក្សាស្វែងយល់ អំពីការធ្វើបច្ចុប្បន្នភាពអំពីដំណើរការនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម នៅខេត្តរតនគិរី ខេត្តស្ទឹងត្រែង មណ្ឌលគិរី និងខេត្តក្រចេះ ។

-អញ្ជើញចុះបេសកកម្មដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់ វឌ្ឍនភាពសំខាន់ៗ បញ្ហាប្រឈមនានា ដែលពាក់ព័ន្ធជាមួយវិស័យអប់រំធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៅខេត្តព្រះសីហនុ និងខេត្តកោះកុង ។

-អញ្ជើញចុះបេសកកម្មសិក្សាស្វែងយល់ស្តីពីរបៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅខេត្តក្រចេះ ។

-អញ្ជើញចុះពិនិត្យការរៀបចំវេទិកាថ្នាក់ខេត្តជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ២ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

- លោកជំទាវ **មាន សំអាន** ឯកឧត្តម **ហុង សុខហួរ** ឯកឧត្តម **ឈិត គីមយាត** ឯកឧត្តម **ម៉ែន -ស៊ីផាន់** និងឯកឧត្តម **សោ ចាន់ដេត** អញ្ជើញទៅបំពេញទស្សនកិច្ចសិក្សាស្វែងយល់អំពី " **តួនាទីរបស់គណបក្សនយោបាយនៅក្នុងសភា** " នៅសាធារណរដ្ឋបារាំង ។

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមកិច្ចពិភាក្សាតុមូលស្តីពី " សន្ធិសញ្ញាពាណិជ្ជកម្មអាវុធ " នៅព្រះរាជាណាចក្រថៃឡង់ដ៍ និងចូលរួមកិច្ចប្រជុំ" AIFOCOM " លើកទី១២ នៅប្រទេសម៉ាឡេស៊ី ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ